http://www.kampucheathmey.com/local-news/2207-2010-09-12-14-14-38.html#

# ពលទាហានខ្មែរដែលរងរបួសដោយការវាយប្រយុទ្ធគ្នាជាមួយទាហានសៀម បានស្លាប់បាត់បង់ជីវិតហើយ

អាទិត្យ, 12 កញ្ញា 2010 21:14

ភ្នំពេញ ៖ ពលទាហានខ្មែរដែលរងរបួសធ្ងន់ដោយការវាយប្រយុទ្ធគ្នាជាមួយទាហាន សៀម នៅព្រំដែនតំបន់ប្រាសាទព្រះវិហារ បានស្លាប់បាត់បង់ជីវិតហើយ កាលពីព្រឹកម៉ោង៩ទៀបភ្លឺ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១០នេះ ដោយសារមុខរបួសចាស់រើឡើងវិញ និងគ្មានប្រាក់ទៅមន្ទីរពេទ្យ ព្យាបាលជម្ងឺ។

ពលទាហានដ៏អភ័ព្វរូបនេះឈ្មោះហា លឿន អាយុ៥៦ឆ្នាំ ប្រពន្ធឈ្មោះឈួន រឿន មានកូន៦នាក់ក្នុងបន្ទុក មានទីលំនៅភូមិត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តបន្ទាយមានជ័យ។ ពល ទាហាន ហា លឿន ចូលបំរើជាកងទ័ពតាំងពីឆ្នាំ១៩៨៨មកម្ល៉េះ ក្នុងកងពលលេខ៩៤៣ ជាអ្នកប្រយុទ្ធជួរមុខ នៅតំបន់ប្រាសាទព្រះវិហារ។ រូបគាត់បានរងរបួសធ្ងន់ក្នុងការវាយប្រយុទ្ធគ្នាមួយប្រាវជាមួយ ទាហានសៀមឈ្លានពានដែនដីខ្មែរ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ ដោយរងរបួសត្រូវគ្រាប់ចំ.ពោះខាងឆ្វេង រួចបញ្ជូនមកសង្គ្រោះនៅមន្ទីរពេទ្យ ១៧៩(ព្រះកេតុមាលា) ហើយមុខរបួសបានរើឡើងវិញ បណ្តាលឲ្យរូបគាត់ធ្លាក់ខ្លួនឈឺជាទម្ងន់ក្នុងអំឡុងពេល១ខែចុង ក្រោយនេះ។

ស្ត្រីជាប្រពន្ធឈ្មោះឈួន រឿន បានរៀបរាប់ប្រាប់កម្ពុជាថ្មីតាមទូរស័ព្ទកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១០ទាំងការទ្រហោយំថា ប្តីរបស់គាត់បានចុកពោះឈឺខ្លាំងខុសពីធម្មតានិងបានផ្តាំផ្ញើ ក្នុងដំណាក់កាលចុងក្រោយនៃជីវិត កាលពីម៉ោង១រំលងអធ្រាត្រថា បើសិនជាគាត់(ពលទាហាន ហា លឿន)ស្លាប់ទៅត្រូវដុតគាត់ រួចយកធាតុទៅជាមួយផង ព្រោះកន្លែងរស់នៅសព្វថ្ងៃ ត្រូវលក់យកប្រាក់សងគេឲ្យអស់ និងផ្តាំផ្ញើឲ្យប្រពន្ធមើលថែកូនៗផង។ អ្នកស្រីក៏បានលង់លក់ក្នុងដំណេកមួយស្របក់ ស្រាប់តែភ្ញាក់ដឹងខ្លួនវិញ ឃើញប្តីស្លាប់បាត់បង់ជីវិតមិនដឹង

តាំងពីពេលណានោះទេ។

ការស្លាប់របស់ពលទាហាន ហា លឿន ជាការស្លាប់ក្នុងបុព្វហេតុតស៊ូប្រយុទ្ធជាមួយពួក សៀម ឈ្លានពានដែនដីខ្មែរ នៅជួរមុខក្នុងសមរភូមិតំបន់ប្រាសាទព្រះវិហារ និងជាវីរភាពមួយគួរឲ្យគោរពក្រៃលែងសម្រាប់ជនរួមជាតិខ្មែរទូទៅ។

ប្រពន្ធ និងកូនៗទាំង៦នាក់ នៃសពពលទាហាន ហា លឿន សូមអំពាវនាវដល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយឧត្តមសេនីយផុតលេខផ្កាយមាស៥ និងលោកជំទាវបណ្ឌិត ឯកឧត្តម លោកជំទាវ លោកឧកញ៉ា នាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ និងសប្បុរសជនរួមជាតិខ្មែរទូទៅ មេត្តាចូលរួមចាប់មគ្គផល និងចូលរួមជាថវិកាក្នុងការធ្វើបុណ្យសពអតីតពលទាហានដ៏អភ័ព្វដែល បានរងរបួស ក្នុងបុព្វហេតុការពារជាតិ មាតុភូមិខ្មែរនៅសមរភូមិមុខរហូតបាត់បង់ជីវិតទៅហើយនោះ និងគ្រាន់បានថវិកាខ្លះសងបំណុលអ្នកស្រុក ភូមិ ដែលក្រុមគ្រួសារពលទាហានបានជំពាក់ផង ព្រោះអត់ពីពលទាហាន ហា លឿនទៅ គាត់ជាប្រពន្ធនិងកូនៗទាំង៦នាក់ មិនដឹង ពឹងពាក់អ្វីទៀតទេ ណាមួយប្រាក់មួយរៀល ដីផ្ទះ ដីស្រែ ចំការ ក៏គ្មានគឺលក់អស់គ្មានសល់អ្វីទេក្នុងអំឡុងពេលព្យាបាលជម្ងឺប្តីកន្លងមក ៕